ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ២៤៨/១៣ - ត្រែតញូស៍ អេឡិកត្រូនិក (ខេមបូឌា)
កាលបរិច្ឆេទនៃសេចក្តីបង្គាប់៖ ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៣

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **សេង រ៉ូចហ៊ុន**
អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **អន ណន**
ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **តាំង ទ្រី**

### ភាគីនៃវិវាទ

**១- ភាគីនិយោជក**

ឈ្មោះ ៖ **ក្រុមហ៊ុន ត្រែតញូស៍ អេឡិកត្រូនិក (ខេមបូឌា)**
អាសយដ្ឋាន ៖ ភូមិព្រៃធំ សង្កាត់ព្រៃស ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០១២ ៩២ ៩៤ ៦៣ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជកចូលរួមផ្តល់ព័ត៌មាន ៖

១- លោក ទូច សុខេម តំណាងក្រុមហ៊ុន
២- លោក ងួន គង់វ៉ា តំណាងក្រុមហ៊ុន

តំណាងភាគីនិយោជកចូលរួមសវនាការលើកទី១ ៖

- លោក ទូច សុខេម តំណាងក្រុមហ៊ុន

តំណាងភាគីនិយោជកចូលរួមសវនាការលើកទី២ ៖

១- លោក វង វៃម៉ាន អគ្គនាយកក្រុមហ៊ុន
២- លោក ងួន គង់វ៉ា តំណាងក្រុមហ៊ុន
៣- លោក ទូច សុខេម តំណាងក្រុមហ៊ុន

**២- ភាគីកម្មករនិយោជិត**

ឈ្មោះ ៖ - **សហព័ន្ធសហជីពស្មារតីកម្មករខ្មែរ**

- **សហជីពស្មារតីកម្មករខ្មែរក្រុមហ៊ុន ត្លែតញូស៊ី អេឡិកត្រូនិក (ខេមបូឌា)**

អាសយដ្ឋាន ៖ ភូមិព្រៃធំ សង្កាត់ព្រៃស ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១២ ៩៣ ៥៩ ៥៦ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិតចូលរួមផ្តល់ព័ត៌មាន ៖

១- លោក សួស សុខា អគ្គលេខាធិការរងសហព័ន្ធសហជីពស្មារតីកម្មករខ្មែរ

២- លោក យឹម ឌីណា ប្រធានសហជីពមូលដ្ឋាន

៣- លោក នួន កុសល្យ អនុប្រធានសហជីព

៤- កញ្ញា សុន វណ្ណៈ លេខាធិការសហជីព

តំណាងកម្មករនិយោជិតចូលរួមសវនាការលើកទី១ ៖

១- លោក ខែម ផានិត មន្ត្រីសហព័ន្ធសហជីពស្មារតីកម្មករខ្មែរ

២- លោក ថោង សឿន មន្ត្រីសហព័ន្ធសហជីពស្មារតីកម្មករខ្មែរ

៣- លោក យឹម ឌីណា ប្រធានសហជីពមូលដ្ឋាន

៤- លោក នួន កុសល្យ អនុប្រធានសហជីព

៥- កញ្ញា សុន វណ្ណៈ លេខាធិការសហជីព

តំណាងកម្មករនិយោជិតចូលរួមសវនាការលើកទី ២ ៖

៥- លោក សួស សុខា អគ្គលេខាធិការរងសហព័ន្ធសហជីពស្មារតីកម្មករខ្មែរ

១- លោក យឹម ឌីណា ប្រធានសហជីពមូលដ្ឋាន

២- លោក នួន កុសល្យ អនុប្រធានសហជីព

៣- កញ្ញា សុន វណ្ណៈ លេខាធិការសហជីព

៤- លោក មាស ងុយ កម្មករ

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- សូមឱ្យក្រុមហ៊ុនបញ្ឈប់ការរើសអើងសហជីពស្មារតីកម្មករខ្មែរ មិនគំរាមកំហែងកម្មករ និងទទួលយកថ្នាក់ដឹកនាំសហជីព លោក យឹម ឌីណា ចូលធ្វើការជាធម្មតាវិញ។

២- សូមឱ្យក្រុមហ៊ុនបើកប្រាក់ឈ្នួលឱ្យបានទៀងទាត់ នៅថ្ងៃទី០៥ ជារៀងរាល់ខែ និងអនុញ្ញាតឱ្យកម្មករចេញពីធ្វើការម៉ោង ៤ម៉ោង០០ នៅថ្ងៃបើកប្រាក់ឈ្នួល។

៣- នៅពេលកម្មករបើកប្រាក់ឈ្នួលមានការបាត់បង់ សូមឱ្យក្រុមហ៊ុនទូទាត់សងវិញ យ៉ាងយូរបីថ្ងៃបន្ទាប់។

៤- សូមឱ្យក្រុមហ៊ុនផ្តល់ប្រាក់ថ្លៃបាយថ្ងៃត្រង់ឱ្យកម្មករចំនួន ៤០០០ រៀល ក្នុងមួយថ្ងៃ។

៥- សូមឱ្យក្រុមហ៊ុនតម្លើងសោហ៊ុយថ្លៃធ្វើដំណើរ ឬស្នាក់នៅចំនួន ១៥ ដុល្លារក្នុងមួយខែ។

៦- សូមឱ្យក្រុមហ៊ុនកាត់ប្រាក់រង្វាន់ធ្វើការទៀងទាត់តាមសមាមាត្រ នៅពេលកម្មករសុំច្បាប់ឈប់សម្រាក ដោយមានច្បាប់។

៧- សូមឱ្យក្រុមហ៊ុនលប់ចោលកិច្ចសន្យាការងារកំណត់ថិរវេលាបីខែ ដោយអនុវត្តកិច្ចសន្យាការងាររយៈពេល មួយឆ្នាំម្តង។

៨- សូមឱ្យក្រុមហ៊ុនគិតប្រាក់ឈ្នួលធ្វើការវេនយប់គុណនឹងពីរ។

៩- សូមឱ្យក្រុមហ៊ុនតម្លើងប្រាក់រង្វាន់ធ្វើការទៀងទាត់ចំនួន ១៥ ដុល្លារក្នុងមួយខែ។

១០- សូមឱ្យក្រុមហ៊ុនរៀបចំឱ្យមានគ្រូពេទ្យប្រចាំការ និងថ្នាំពេទ្យគ្រប់គ្រាន់។

១១- សូមឱ្យក្រុមហ៊ុនអនុញ្ញាតច្បាប់កម្មករឱ្យមានភាពការងាយស្រួលតាមការជាក់ស្តែង។

១២- ការធ្វើការថែមម៉ោងផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត ដោយពុំមានការបង្ខិតបង្ខំកម្មករ។

១៣- សូមឱ្យក្រុមហ៊ុនដករដ្ឋបាលឈ្មោះ ខេម ចេញពីការងារព្រោះបានគំរាមកំហែងកម្មករ និងបញ្ឈប់ កម្មករស្រេចតែចិត្ត។

១៤- ពេលកម្មករឈឺមានសំបុត្រពេទ្យរដ្ឋ និងពេទ្យបង្អែកត្រឹមត្រូវ សូមក្រុមហ៊ុនរក្សាប្រាក់ឈ្នួល និងអត្ថ ប្រយោជន៍ផ្សេងៗនៅដដែល។

១៥- សូមក្រុមហ៊ុនរក្សាប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗនៅដដែល ក្នុងកំឡុងពេលកម្មករចូលរួមធ្វើ កូដកម្ម ហើយមិនត្រូវធ្វើការគុំគួនកម្មករដែលបានចូលរួមធ្វើកូដកម្មទេ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែក ទីពីរ(ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៣៦ កប/ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ (អាណត្តិទី៥)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ១៤៣២ កប/អក/វក ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៣ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៣។

**សវនាការ និង សង្ខេបនីតិវិធី**

**ទីកន្លែងសវនាការ** ៖ ក្រុមប្រឹក្សាអាជ្ញាកណ្តាល “ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ” ។

**កាលបរិច្ឆេទចូលរួមប្រជុំផ្តល់ព័ត៌មាន** ៖ ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៣ (វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក ) ។

**កាលបរិច្ឆេទសវនាការ** ៖ - ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១៣ (វេលាម៉ោង ០២ និង ០០ នាទី រសៀល ) ។
- ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៣ (វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក ) ។

**បញ្ហានៃនីតិវិធី** ៖

នៅថ្ងៃទី០១ ខែវិច្ឆកា ឆ្នាំ២០១៣ នាយកដ្ឋានវិវាទការងារ បានទទួលពាក្យបណ្តឹងតាមទូរស័ព្ទពីសហព័ន្ធសហជីពស្មារតីកម្មករខ្មែរ ស្តីពីកម្មករនិយោជិតធ្វើកូដកម្មទាមទារឱ្យក្រុមហ៊ុនកែលំអនូវលក្ខខណ្ឌការងារ ឱ្យបានល្អប្រសើរ។ បន្ទាប់ពីបានទទួលបណ្តឹងនេះ នាយកដ្ឋានវិវាទការងារបានចាត់មន្ត្រីជំនាញ ឱ្យធ្វើការដោះស្រាយវិវាទការងារនេះជាបន្តបន្ទាប់ និងបានធ្វើការផ្សះផ្សាជាលើកចុងក្រោយនៅថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៣ ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នាទេ ទៅលើការទាមទារចំនួន ១៥ ចំណុចនេះ។ ចំណុចមិនសះជាចំនួន ១៥ ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៣ តាមរយៈរបាយការណ៍ ស្តីពីការដោះស្រាយវិវាទការងាររួម លេខ ១៤៣២ ក.ប/អក/វក ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៣។

កូដកម្មនៅតែបន្ត បន្ទាប់ពីសំណុំរឿងត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបញ្ជា លេខ ០៤៥/១៣ កបអ. ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៣ ឱ្យកូដករផ្អាកជាបន្ទាន់នូវការធ្វើកូដកម្មនៅក្រុមហ៊ុន ត្លែតញ៉ូស៍ អេឡិចត្រូនិច (ខេមបូឌា) រហូតដល់នីតិវិធីនៃអាជ្ញាកណ្តាលត្រូវបានចប់សព្វគ្រប់តាមនីតិវិធីច្បាប់ ហើយកូដករទាំងអស់ត្រូវត្រឡប់ចូលធ្វើការវិញ ចាប់ពីព្រឹកថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៣ តទៅ តាមវេនរបស់ខ្លួន។ កូដករនៅបន្តធ្វើកូដកម្មដដែល ដោយកូដករមិនបានគោរពតាមសេចក្តីបញ្ជា របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនេះទេ។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអញ្ជើញភាគីទាំងពីរមកសាកសួរព័ត៌មានបន្ថែម ក្នុងកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្តាល នាថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៣ នៅវេលាម៉ោង ០៨៖៣០ នាទី ព្រឹក។ ភាគីទាំងពីរមានវត្តមានតាមការអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ក្នុងកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្តាល ភាគីកម្មករនិយោជិតបានអះអាងថា កម្មករនិយោជិតនឹងឈប់ធ្វើកូដកម្ម ហើយនាំគ្នាចូលធ្វើការវិញ។ ចំណែកភាគីនិយោជកបានលើកឡើងថា និយោជកក៏មិនឡុកអៅក្រុមហ៊ុនដែរ។ ដូចនេះ នៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៣ នៅវេលាម៉ោង ២ រសៀល ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំណត់ថ្ងៃសវនាការលើកទី១។

លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការលើកទី១ នៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៣ វេលាម៉ោង ២ រសៀល តាមកាលកំណត់ ដើម្បីសាកសួរពីព័ត៌មានទាក់ទងនឹងអង្គហេតុនៃចំណុចវិវាទទាំង ១៥ ចំណុចនេះ។ ភាគីទាំងពីរមានវត្តមាននៅថ្ងៃសវនាការលើកទី១ តាមការកោះអញ្ជើញរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល។ នៅថ្ងៃសវនាការលើកទី១ ភាគីនិយោជកបានអះ

អាងថា កម្មករនិយោជិតនៅតែបន្តធ្វើកូដកម្មនៅក្រុមហ៊ុន គ្លែតញូស៍ អេឡិចត្រូនិច (ខេមបូឌា) មកទល់ថ្ងៃសវនាការលើកទី១ គឺពួកគាត់មិនព្រមធ្វើការតាមការងារដែលនិយោជកបានដាក់ឱ្យពួកគាត់ធ្វើនោះទេ។ នៅក្នុងសវនាការលើកទី១ដដែល ភាគីនិយោជកបានអះអាងថា ខ្លួនទើបតែបានទទួលដំណឹងភ្លាមនេះថា ក្រុមកម្មករនិយោជិត ដែលជាគ្នាគាត់នេះ ទើបតែបានបង្កសកម្មភាពមួយចំនួនថែមទៀត ដូចជាបង្ហូរទឹកក្នុងបន្ទប់ទឹកចោល វាយបំបែកចានបង្គន់ និងថ្មសំលៀងកាំបិតរបស់ក្រុមហ៊ុន ដូចនេះ ភាគីនិយោជកមិនអាចចូលរួមដោះស្រាយវិវាទនេះនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលបានឡើយ ហើយភាគីនិយោជកក៏បានថតរូបភាពវីឌីអូ(Video) ជាភស្តុតាងផងដែរ។ ចំណែកឯភាគីកម្មករនិយោជិតបានអះអាងថា កម្មករនិយោជិតមិនបាននៅបន្តធ្វើកូដកម្ម ដូចការលើកឡើងរបស់ភាគីនិយោជកទេ ពោលគឺ កម្មករនិយោជិតបានត្រលប់ចូលធ្វើការវិញ ប៉ុន្តែនិយោជកមិនមានការងារឱ្យកម្មករនិយោជិតទាំងនេះធ្វើ។ ភាគីទាំងពីរបានអះអាងថា ពួកគាត់សុទ្ធតែមានភស្តុតាង ដើម្បីគាំទ្រការអះអាងរៀងៗខ្លួន ព្រមទាំងសន្យាថា នឹងដាក់ភស្តុតាងទាំងនេះមកក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិនិត្យ តាមការកំណត់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។

ដោយសារការលើកឡើងរបស់ភាគីទាំងពីរ មានលក្ខណៈខុសគ្នា និងធ្វើការចោទប្រកាន់គ្នាទៅវិញទៅមកបែបនេះ ទើបក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបង្គាប់ឱ្យភាគីទាំងពីរដាក់ភស្តុតាង ដើម្បីគាំទ្រតាមការអះអាងរបស់ខ្លួនរៀងៗខ្លួន មិនឱ្យយឺតយ៉ាវជាងថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៣។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំណត់សវនាការលើកទី២ នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៣។ ដល់ថ្ងៃកំណត់ដាក់ភស្តុតាង ភាគីទាំងពីរនៅតែមិនបានដាក់ភស្តុតាង ដើម្បីគាំទ្រការអះអាងរបស់ខ្លួនទេ។ ដល់ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៣ ជាថ្ងៃកំណត់សវនាការលើកទី២ គឺភាគីនិយោជកបានលើកឡើងថា និយោជកមានវីឌីអូ(Video) ដែលអាចបង្ហាញថា កម្មករនិយោជិតមិនព្រមធ្វើការ ព្រមទាំងបង្កសកម្មភាពមួយចំនួន ដូចជា បង្ហូរទឹកក្នុងបន្ទប់ទឹកចោល ព្រមទាំងវាយបំបែកចានបង្គន់ និងថ្មសំលៀងកំបិតរបស់ក្រុមហ៊ុន។ ភាគីកម្មករនិយោជិតបានឆ្លើយតបទៅភាគីនិយោជកវិញ កម្មករនិយោជិតដែលបង្កសកម្មភាពក្នុងក្រុមហ៊ុន ដូចជា បង្ហូរទឹកក្នុងបន្ទប់ទឹកចោល ព្រមទាំងវាយបំបែកចានបង្គន់ និងថ្មសំលៀងកំបិតរបស់ក្រុមហ៊ុនជាដើម គឺមិនមែនកម្មករនិយោជិតដែលធ្លាប់ធ្វើការកូដកម្មទេ។ រីឯភាគីកម្មករនិយោជិតបានអះអាងថា កម្មករនិយោជិតក៏មានភស្តុតាងដែលបញ្ជាក់ថា និយោជកមិនមានការងារឱ្យកម្មករនិយោជិតធ្វើផងដែរ។

ភាគីទាំងពីរយល់ព្រមពន្យារថ្ងៃចេញសេចក្តីបង្គាប់អាជ្ញាកណ្តាល ពីថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ទៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៣។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

**ភស្តុតាង**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖គ្មាន**

ឯកសារ វត្ថុតាង ដែលក្រុមអាជ្ញាកណ្ដាលយកមកពិចារណាមាន

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

- លិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៣ របស់នាយកក្រុមហ៊ុន ឡែតញូស៍ អេឡិកត្រូនិក (ខេមបូឌា) ផ្ទេរសិទ្ធិជូនលោក ទូច សុខេម ដើម្បីចាត់ចែងដោះស្រាយវិវាទ និងសម្រេចលើបញ្ហាគ្រប់យ៉ាងតាមផ្លូវច្បាប់។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖ គ្មាន

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ឡែតញូស៍ អេឡិកត្រូនិក (ខេមបូឌា) លេខ ១៤៣២ កប/អក/វក ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៣។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន ឡែតញូស៍ អេឡិកត្រូនិក (ខេមបូឌា) ចុះថ្ងៃទី០៧ ខែ វិច្ឆិកា ឆ្នាំ២០១៣។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតលេខ ១២៣៣ កប/អក/វក ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៣ របស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល អញ្ជើញនាយកក្រុមហ៊ុន ឡែតញូស៍ អេឡិកត្រូនិក (ខេមបូឌា) ដើម្បីមកជ្រើសរើសអាជ្ញាកណ្តាល។

២- សេចក្តីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៤៥/១៣ កបអ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៣។

៣- លិខិតអញ្ជើញភាគីនិយោជកចូលរួមផ្តល់ព័ត៌មានលំអិត លេខ ១២៥០ កប/អក/វក/លកអ. ចុះថ្ងៃទី២២ ខែ វិច្ឆិកា ឆ្នាំ២០១៣ ។

៤- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមផ្តល់ព័ត៌មានលំអិត លេខ ១២៥១ កប/អក/វក/លកអ. ចុះថ្ងៃទី២២ ខែ វិច្ឆិកា ឆ្នាំ២០១៣។

៥- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ១២៦៤ កប/អក/វក/លកអ. ចុះថ្ងៃទី០៧ ខែ វិច្ឆិកា ឆ្នាំ២០១៣ ។

៦- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ១២៦៥ កប/អក/វក/លកអ. ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៣។

៧- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលើកទី២ លេខ ១២៩៦ កប/អក/វក/លកអ. ចុះថ្ងៃទី ០៥ ខែធ្នូ ឆ្នាំ២០១៣ ។

៨- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលើកទី ២ លេខ ១២៩៧ កប/អក/វក/លកអ. ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៣។

**អង្គហេតុ ៖**

មិនមានការរកឃើញអង្គហេតុ ទាក់ទងទៅនឹងចំណុចបញ្ហាវិវាទនៅក្នុងរបាយការណ៍មិនសះជា ដែលនាយកដ្ឋានវិវាទការងារ បានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ដោយសារក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនបានដំណើរការសវនាការ ដែលពាក់ព័ន្ធនឹងអង្គហេតុនៃចំណុចវិវាទទាំង ១៥ ចំណុចនេះ ។

**ហេតុផលនៃសេចក្តីសម្រេច ÷**

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើនៅតែអាចបន្តនីតិវិធីអាជ្ញាកណ្តាលរបស់ខ្លួនដែរ ឬទេ?

ប្រការ ២០ នៃប្រកាសលេខ ០៩៩ សកបយ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចែងថា ៖ "*ក្នុងអំឡុងពេលនៃដំណើរការរបស់ក្រុមអាជ្ញាកណ្តាល ភាគីវិវាទទាំងឡាយត្រូវផ្អាករាល់វិធានការវិវាទ ដូចជាកូដកម្ម ឬឡុកអៅ (ដូចមានចែងក្នុងមាត្រា ៣១៨ នៃច្បាប់ស្តីពីការងារ)* ***ឬវិធានការដទៃទៀត ដែលអាចធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរ*** *។ ភាគីទាំងនេះត្រូវតែចូលរួមគ្រប់កិច្ចប្រជុំទាំងឡាយដែលក្រុមអាជ្ញាកណ្តាលបានអញ្ជើញឱ្យចូលរួម* " ។

យោងតាមប្រការ ២០ នៃប្រកាសលេខ ០៩៩ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីវិវាទត្រូវផ្អាករាល់វិធានការវិវាទ ដូចជាកូដកម្ម ឬឡុកអៅ ឬវិធានការដទៃទៀត ដែលអាចធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរ នៅក្នុងដំណើរការអាជ្ញាកណ្តាល ។

ក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអញ្ជើញភាគីទាំងពីរមកចូលរួមកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្តាលនាថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៣ នៅវេលាម៉ោង ០៨៖៣០ នាទី ព្រឹក ។ ភាគីទាំងពីរមានវត្តមាន តាមការអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ។ ក្នុងកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្តាល ភាគីកម្មករនិយោជិតបានលើកឡើងថា កម្មករនិយោជិតនឹងឈប់ធ្វើកូដកម្ម ហើយនាំគ្នាចូលធ្វើការវិញ ។ ចំណែកភាគីនិយោជកថា និយោជកក៏មិនឡុកអៅ ក្រុមហ៊ុនដែរ ។ នៅក្នុងកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្តាលនេះដែរ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ក៏បានកំណត់ថ្ងៃសវនាការ(លើកទី១)គឺនៅថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៣ ។

នៅថ្ងៃសវនាការលើកទី១ នៅថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៣ នៅវេលាម៉ោង ២ រសៀល ភាគីនិយោជកបានអះអាងថា កម្មករនិយោជិតនៅតែបន្តធ្វើកូដកម្ម នៅក្រុមហ៊ុន ឆ្លែតញូស៍ អេឡិចត្រូនិច (ខេមបូឌា) គឺពួកគាត់មិនព្រមធ្វើការតាមការងារដែល និយោជកបានដាក់ឱ្យពួកគាត់ធ្វើនោះទេ ។ នៅអំឡុងពេលសវនាការលើកទី១ ភាគីនិយោជកក៏បានអះអាងថា ខ្លួនទើបតែបានទទួលដំណឹងថា ក្រុមកម្មករនិយោជិតជាគ្នាពួកគាត់ ទើបតែបានបង្កសកម្មភាពមួយចំនួនថែមទៀត ដូចជាបង្ហូរទឹកក្នុងបន្ទប់ទឹកចោល ព្រមទាំងវាយបំបែកចានបង្គន់ នឹងថ្មសំលៀងកាំបិតរបស់ក្រុមហ៊ុន ដូចនេះ ភាគីនិយោជកមិនអាចចូលរួមដោះស្រាយវិវាទនេះ នៅក្រុមប្រឹក្សាអាជ្ញាកណ្តាលបានឡើយ ហើយភាគីនិយោជកក៏បានថតរូបភាពវិឌីអូ(Video) ជាភស្តុតាងផងដែរ ។ ចំណែកឯភាគីកម្មករនិយោជិតបានអះអាងថា កម្មករនិយោជិតមិនបាននៅបន្តធ្វើកូដកម្ម ដូចការលើកឡើងរបស់ភាគីនិយោជកទេ ពោលគឺកម្មករ និយោជិតបានត្រលប់ចូលធ្វើការវិញ ប៉ុន្តែ និយោជកមិនមានការងារឱ្យកម្មកនិយោជិតទាំងនេះធ្វើ ។ ភាគីកម្មករនិយោជិតបានឆ្លើយ

តបទៅភាគីនិយោជកវិញថា កម្មករនិយោជិតដែលបង្កសកម្មភាពក្នុងក្រុមហ៊ុន ដូចជាបង្ហូរទឹកក្នុងបន្ទប់ទឹកចោល ព្រមទាំងវាយបំបែកចានបង្គន់ និងថ្មសំលៀងកាំបិតរបស់ក្រុមហ៊ុន គឺមិនមែនកម្មករនិយោជិតដែលធ្លាប់ធ្វើការកូដកម្មទេ។ លើសពីនេះ ភាគីទាំងពីរអះអាងថា ពួកគាត់មានភស្តុតាង ដើម្បីគាំទ្រការអះអាងរៀងៗខ្លួន។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលកត់សំគាល់ឃើញថា ភាគីទាំងពីរមានការអះអាងផ្ទុយគ្នា ដែលមិនបានបង្ហាញឱ្យឃើញនូវសុច្ឆន្ទៈក្នុងការដោះស្រាយវិវាទទេ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏បានបង្គាប់ឱ្យភាគីទាំងពីរដាក់ភស្តុតាងរៀងៗខ្លួន ដើម្បីគាំទ្រការអះអាងផ្ទុយគ្នា ដោយកំណត់ថ្ងៃដាក់ភស្តុតាងមិនឱ្យយឺតយ៉ាវជាងថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៣ និងកំណត់សវនាការលើកទី២ នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៣ ដើម្បីស្វែងរកការពិតថា ស្ថានភាពដែលកើតឡើងក្នុងក្រុមហ៊ុន។ ដល់ថ្ងៃកំណត់ដាក់ភស្តុតាង ភាគីទាំងពីរមិនបានដាក់ភស្តុតាង ដើម្បីគាំទ្រការអះអាងរបស់ខ្លួនទេ។

ផ្អែកតាមសេចក្តីបង្គាប់អាជ្ញាកណ្តាលមុនៗ ភាគីដែលធ្វើការអះអាង ឬចោទប្រកាន់ គឺមានបន្ទុកភស្តុតាង។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល *លេខ ៧៩/០៥-អេវើរប្រ៊ីត, លេខ ១០១/០៨-ជីឌីអ៊ីម ហេតុផលចំណុចវិវាទទី១ និងទី២, លេខ ១០៨/០៨-ហ៊ូហ្គោ ហេតុផលចំណុចវិវាទទី៤, លេខ ១៦៣/០៩-តាកហ្វាត ហេតុផលចំណុចវិវាទទី២, លេខ ១៦៨/០៩-ទឹកថ្លា ផ្លាហ្សា ហេតុផលចំណុចវិវាទទី២ និងលេខ ១១៥/១០-ជី-ហ្វម៉ូស ហេតុផលចំណុចវិវាទទី១៨ និង១៤៨/១១-ដាយ យ៉ាំង*)។

ក្នុងសំណុំរឿងនេះ ភាគីទាំងពីរបានអះអាងផ្ទុយគ្នាស្តីពីការដែលកម្មករនិយោជិតបន្តកូដកម្មក្នុងក្រុមហ៊ុន ឬនិយោជកមិនមានការងារឱ្យកម្មករនិយោជិតធ្វើ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីទាំងពីរមិនបានព្យាយាមអស់លទ្ធភាពនៅក្នុងការបង្ហាញភស្តុតាងទាំងឡាយគាំទ្រអំណះអំណាងរៀងៗខ្លួន ទាក់ទងនឹងបញ្ហានេះ ដើម្បីឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលជឿតាមការលើកឡើងរបស់ភាគីទាំងពីរនោះទេ។ ទោះជាយ៉ាងណា ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ភាគីទាំងពីរកំពុងធ្វើការចោទប្រកាន់គ្នាទៅវិញទៅមក ដោយភាគីកម្មករចោទថា និយោជកមិនបានផ្តល់ការងារឱ្យកម្មករធ្វើ ប៉ុន្តែ ភាគីនិយោជកចោទថា កម្មករនិយោជិតបានមិនព្រមធ្វើការតាមការងារ ដែលនិយោជកបានដាក់ឱ្យពួកគាត់ធ្វើនោះទេ ព្រមទាំងបង្កសកម្មភាពមួយចំនួន ដូចជាបង្ហូរទឹកក្នុងបន្ទប់ទឹកចោល ព្រមទាំងវាយបំបែកចានបង្គន់នឹងថ្មសំលៀងកំហិតរបស់ក្រុមហ៊ុន។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការអះអាងផ្ទុយគ្នារវាងភាគីកម្មករនិយោជិត និងភាគីនិយោជក គឺបានបង្ហាញថា ភាគីទាំងពីរពុំមានចេតនាដោះស្រាយវិវាទនេះទេ និងបង្កើតឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរ។

យោងតាមប្រការ ២០ នៃប្រកាសលេខ ០៩៩ សកបយ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈខាងលើ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបញ្ចប់ដំណើរការអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះ។

យោងតាមអង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ៖

THE ARBITRATION COUNCIL

## សម្រេច និង បង្គាប់

- បញ្ចប់ដំណើរការអាជ្ញាកណ្តាលក្នុងសំណុំរឿងលេខ ២៤៨/១៣-គ្លែតញូស៍ អេឡិកត្រូនិក (ខេមបូឌា) ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក

ឈ្មោះ ៖ **សេង ឌួចហ៊ុន**

ហត្ថលេខា ៖ ---------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត

ឈ្មោះ ៖ **អន ណាន**

ហត្ថលេខា ៖ ---------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល

ឈ្មោះ ៖ **តាំង ទ្រី**

ហត្ថលេខា ៖ ---------------------------------

THE ARBITRATION COUNCIL